# សិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពីជីវសុវត្ថិភាពមន្ទីរពិសោធន៍ និងការគ្រប់គ្រង ជីវហានិភ័យផ្នែកទី១

# ផ្នែកទី ១ ៖ ជីវសុវត្ថិភាពកម្រិតមូលដ្ឋាន

## ១.៩. ការឆ្លើយតបបន្ទាន់ក្នុងពេលមានអាសន្ន

# នៅចុងបញ្ចប់នៃម៉ូឌុលនេះ អ្នកគួរតែមានសមត្ថភាព៖

- យល់ច្បាស់ថា ការធ្វើផែនការសំរាប់គ្រោះមានឧបទ្ទវហេតុ និងការត្រៀមទុកជាមុន គឺការចាំបាច់ខានមិនបាន សម្រាប់ការឆ្លើយតបចំពោះឧបទ្ទវហេតុប្រកបដោយប្រសិទ្ធភាព
- ស្គាល់អំពីធាតុផ្សំដែលត្រូវដាក់បញ្ចូលនៅក្នុងផែនការ ការឆ្លើយតបពេលមានឧបទ្ទវហេតុ
- សរសេររបាយការណ៍ឧបទ្ទវហេតុ
- ដឹង និងអនុវត្តនីតិវិធីពេលមានអាសន្នសម្រាប់ឧបទ្ទវហេតុដែលច្រើនកើតមាននៅក្នុងមន្ទីរពិសោធន៍

# ទិដ្ឋភាពរួម

**ផែនការបន្ទាន់ចំពោះហេតុការណ៍មិនបានគ្រោងទុក និងផែនការពេលមានអាសន្ន**

- សារៈសំខាន់នៃផែនការពេលមានអាសន្ន
- ការពិពណ៌នាអំពីមាតិការ និងនីតិវិធីនៅក្នុងផែនការពេលមានអាសន្ន
- ប្រអប់សង្គ្រោះបឋមមន្ទីរពិសោធន៍
- លំហាត់អនុវត្ត

**នីតិវិធីពេលមានអាសន្ន**

- ការកំពប់វត្ថុធាតុជីវសាស្ត្រ
- ការកំពប់វត្ថុធាតុគីមី
- ការកំពប់វត្ថុធាតុវិទ្យុសកម្ម
- ដំបៅដោយសារការមុតអគ្គីភ័យ
- លំហាត់អនុវត្ត

# ផែនការត្រៀមនិងឆ្លើយតបពេលមានអាសន្ន

- ដាក់បញ្ចូលទៅផ្នែកផ្សេងៗនៃប្រព័ន្ធគ្រប់គ្រងហានិភ័យទាំងមូល
- គោលបំណង
  - ដើម្បីត្រៀមខ្លួនសម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះហេតុការកើតឡើងដោយចៃដន្យ ក្នុងគោលបំណងកំណត់ផលវិបាកជាអវិជ្ជមាន និងជួយសម្រួលដល់ការរៀបចំឡើងវិញក្រោយគ្រោះមហន្តរាយ("ការបន្តដំណើរការការងារ") ។
- អត្ថប្រយោជន៍នៃការធ្វើផែនការសម្រាប់ពេលមានអាសន្ន
  - វាយតម្លៃហានិភ័យស៊ីជម្រៅបន្ថែមទៀត ដោយផ្តោតទៅការយកចិត្តទុកដាក់លើអ្វីមិនល្អដែលអាចកើតមាន
  - ការរកអោយឃើញ និងការកែតម្រូវលើបញ្ហាខ្វះខាត
  - បង្កើនការយល់ដឹងអំពីសុវត្ថិភាព
  - ការអភិវឌ្ឍការធ្វើការងារជាក្រុម

# វដ្តនៃការគ្រប់គ្រងគ្រោះអាសន្ន



# ការធ្វើផែនការ និងការឆ្លើយតបគ្រោះអាសន្ន

## កម្រិតនៃការឆ្លើយតបគ្រោះអាសន្ន

**កម្រិតទី ១៖** គ្រោះថ្នាក់តូចនៅនឹងកន្លែង ឬបរិវេណតូច។ គ្រោះថ្នាក់នេះ អាចដោះស្រាយបានយ៉ាងឆាប់រហ័សដោយប្រើធនធានរបស់ស្ថាប័នដែលមានស្រាប់ ឬជំនួយពីក្រៅតិចតួច

**កម្រិតទី ២៖** ហេតុការណ៍អាសន្នដែលអាចរំខានដល់រចនាសម្ព័ន្ធអង្គភាពនៅផ្នែកសំខាន់ៗ។ ហេតុការអាសន្នតម្រូវនេះ តម្រូវឲ្យមានការជួយជ្រោមជ្រែងពីអង្គភាពខាងក្រៅ។

**កម្រិតទី ៣៖** គ្រោះមហន្តរាយដែលពាក់ព័ន្ធជាមួយអង្គភាពទាំងមូល និងសហគមន៍ជុំវិញ។ ប្រតិបត្តិការជាប្រក្រតីរបស់អង្គភាពត្រូវបានផ្អាក។ ផលប៉ះពាល់មានទំហំធំធេង និងស្មុគស្មាញ។ ដំណោះស្រាយទាន់ពេលវេលានៃស្ថានភាពគ្រោះមហន្តរាយតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការទូទាំងអង្គភាពទាំងមូល រួមទាំងការសម្របសម្រួលយ៉ាងទូលំទូលាយ និងការគាំទ្រពីភ្នាក់ងារក្នុងមូលដ្ឋាន។

# ការត្រៀមខ្លួនសម្រាប់ពេលមានអាសន្ន

ផ្អែកលើការវាយតម្លៃហានិភ័យ

- ការកំណត់រកប្រភពគ្រោះថ្នាក់
- ប្រភេទគ្រោះថ្នាក់ដែលអាចកើតឡើង *"តើអ្វីមិនល្អខ្លះដែលអាចកើតមាន?"* ៖ ពិនិត្យមើលរបាយការណ៍ និងស្ថិតិគ្រោះថ្នាក់ពីក្នុងបរិយាកាសប្រហាក់ប្រហែលអ្វីដែលមានប្រយោជន៍
- ភាពដែលអាចកើតមានឡើង

ការធ្វើផែនការ

- ការកំណត់រកសេណារីយ៉ូគ្រាអាសន្ន ដែលទំនងជាអាចកើតមាន
- ការបង្កើតនីតិវិធីដែលសម្របទៅនឹងពេលមានអាសន្ន រួមទាំងនិយមន័យនៃការទទួលខុសត្រូវ និងតម្រូវការផ្គត់ផ្គង់
- ការបណ្ដុះបណ្ដាល និងការហាត់សម
- ការសម្របឲ្យត្រូវតាមស្ថានភាពជាក់ស្ដែង(ឧ. ដោយផ្អែកលើលំហាត់ហ្វឹកសមកំរិតមូលដ្ឋាន)

# ការធ្វើផែនការសម្រាប់ពេលមានអាសន្ន

ផែនការនេះគួរតែផ្តល់នីតិវិធីប្រតិបត្តិការសម្រាប់៖

1. គ្រោះមហន្តរាយធម្មជាតិ ឧ. អគ្គីភ័យ ទឹកជំនន់ រញ្ជួយដី និងការផ្ទុះ
2. ការគ្រប់គ្រងឧបទ្ទវហេតុនៃការប្រឈម និងការគ្រប់គ្រងការសម្លាប់មេរោគ
3. ការជន្លៀសជាបន្ទាន់ មនុស្ស និងសត្វចេញពីបរិវេណក្នុងពេលមានអាសន្ន
4. ការព្យាបាលបន្ទាន់ផ្នែកវេជ្ជសាស្ត្រចំពោះអ្នកដែលប៉ះពាល់ និងរងរបួស
5. ការអង្កេតតាមដានផ្នែកវេជ្ជសាស្ត្រចំពោះ ទៅលើជនដែលរងប៉ះពាល់ជាមួយសារធាតុគ្រោះថ្នាក់
6. ការគ្រប់គ្រងផ្នែកគ្លីនិកលើជនដែលរងការប៉ះពាល់ជាមួយសារធាតុគ្រោះថ្នាក់
7. ប្រតិបត្តិការបន្តក្រោយពេលឧបទ្ទវហេតុ

# ចំណុចគួរពិចារណានៅក្នុងផែនការពេលមានអាសន្ន

- ការកំណត់អត្តសញ្ញាណមេរោគមានហានិភ័យខ្ពស់
- ទីតាំងនៃតំបន់មានហានិភ័យខ្ពស់ ឧ. មន្ទីរពិសោធន៍ កន្លែងស្តុក កន្លែងសម្រាប់សត្វ
- ការកំណត់អត្តសញ្ញាណបុគ្គលិក និងប្រជាជនដែលប្រឈមនឹងហានិភ័យ
- ការកំណត់អត្តសញ្ញាណបុគ្គលិកទទួលខុសត្រូវ និង ភារកិច្ចរបស់ពួកគេ

# ចំណុចគួរពិចារណាក្នុងការត្រៀមខ្លួនសម្រាប់ពេលមានអាសន្ន(១)

សេណារីយ៉ូគួរតែ

- ទូលំទូលាយគ្រប់គ្រាន់ ដើម្បីអាចដាក់បញ្ចូលរាល់ស្ថានភាពដែលអាចកើតមាន
- ជាក់លាក់គ្រប់គ្រាន់ ដើម្បីចៀសវាងការយល់ច្រឡំណាមួយ
- ត្រូវការតុល្យភាពល្អរវាងភាពពេញលេញ និងភាពជាក់លាក់

- នីតិវិធីពេលមានអាសន្នគួរមានភាពជាក់លាក់ និងច្បាស់លាស់ ដោយទុកចន្លោះសម្រាប់ការសម្របទៅតាមស្ថានភាពជាក់ស្តែង
- ការកំណត់តួនាទី និងការទទួលខុសត្រូវបានច្បាស់លាស់ល្អគឺជាគន្លឹះ ដើម្បីអាចឆ្លើយតបពេលមានអាសន្នបានប្រកបដោយប្រសិទ្ធភាព

# ចំណុចគួរពិចារណាក្នុងការត្រៀមខ្លួនសម្រាប់ពេលមានអាសន្ន(២)

## ការផ្គត់ផ្គង់

- សម្ភារៈទាំងអស់ដែលចាំបាច់ដើម្បីអនុវត្តអន្តរាគមន៍គួរត្រូវបានកំណត់ និងរាយឈ្មោះ ហើយត្រូវមានជាស្រេចនៅតាមទីតាំងសមស្រប
- ចាំបាច់ត្រូវដាក់បំពេញស្តុកសម្ភារៈជំនួសវិញ ក្រោយពេលអន្តរាគមន៍

## ការបណ្តុះបណ្តាល និងការហាត់សម

- មានសារៈសំខាន់ខ្ពស់ ជាពិសេសសម្រាប់នីតិវិធីពេលមានអាសន្នដែលវែង និងស្មុគស្មាញ៖ អន្តរាគមន៍ពេលមានអាសន្នដែលកម្រកើតមាន និងមានសក្តានុពលបង្កគ្រោះថ្នាក់ ហើយអ្នកឆ្លើយតបចាំបាច់ត្រូវដឹងឲ្យច្បាស់អំពីអ្វីដែលត្រូវធ្វើ និងត្រូវធ្វើដោយរបៀបណា
- ដោយឡែក លំហាត់សមសម្រាប់ពេលមានអាសន្ន ជួយបង្កើនទំនុកចិត្ត និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត ហើយក៏អាចជួយកែលម្អនីតិវិធីឲ្យកាន់តែប្រសើរឡើងផងដែរ

# ការផ្គត់ផ្គង់៖ ឧបករណ៍ពេលមានអាសន្ន

- ឧបករណ៍កំណត់រកអគ្គីភ័យ៖ ធ្វើការប្រើសាកល្បង និងថែទាំ
- ប្រព័ន្ធបាញ់ពន្លត់អគ្គីភ័យ (អាចមាន)
  - ថែទាំ
  - មិនណែនាំឲ្យមានក្នុងមន្ទីរពិសោធន៍ BSL3 (សារធាតុរាវពិបាកគ្រប់គ្រង)
- ប្រដាប់ពន្លត់អគ្គីភ័យ៖ ការបណ្តុះបណ្តាលបុគ្គលិក (ជាក់លាក់) អំពីរបៀបប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព
- កន្លែងមុជទឹកពេលមានអាសន្ន៖គួរមានទីតាំងនៅច្រកចូលមន្ទីរពិសោធន៍ ឬរបៀងមន្ទីរពិសោធន៍, ជាពិសេសប្រើសម្រាប់សុវត្ថិភាពជាតិគីមី, អាចប្រើបានផងដែរក្នុងករណីរលាកធ្ងន់ធ្ងរ ឬប៉ះពាល់សារធាតុជីវសាស្ត្រធ្ងន់ធ្ងរ (ឧ. ការខ្ទាតច្រើន)

# ការផ្គត់ផ្គង់៖ ឧបករណ៍សម្រាប់គ្រោះអាសន្ន

កន្លែងលាងភ្នែក៖ ភ្នែក ឬមុខប៉ះពាល់ជាមួយសារធាតុគីមី ឬសារធាតុជីវសាស្ត្រ

- ជាទូទៅភ្ជាប់ជាមួយអាងទឹក ឬកន្លែងមុជទឹកពេលមានអាសន្ន
- ជាការល្អគួរមានទីតាំងនៅក្នុងមន្ទីរពិសោធន៍ជិតច្រកចេញ
- ចាំបាច់ត្រូវមានការចុចទឹកឲ្យហូរជាទៀងទាត់ ដើម្បីចៀសវាងការកកើតបាក់តេរី ឬ protozoal (ឧ. យ៉ាងហោចណាស់មួយខែម្តង)
- អាចមានជម្រើសផ្សេងទៀត (ឧ. Diphoterine dispensers)

# ការផ្គត់ផ្គង់៖ ឧបករណ៍សម្រាប់គ្រោះអាសន្ន

ប្រអប់ប្រើសម្រាប់ករណីមានកំពប់៖ សម្រាប់ការកំពប់សារធាតុជីវសាស្ត្រ និង/ឬសារធាតុគីមី

- សម្ភារៈដែលសមស្របតាមតម្រូវការជាក់ស្តែងត្រូវបានកែសម្រួលទៅតាមសេចក្តីត្រូវការ
- ទីតាំងទុកដាក់អាស្រ័យទៅតាមនីតិវិធី

ប្រអប់សង្គ្រោះបឋម៖ ការបណ្តុះបណ្តាលដល់បុគ្គលិកដែលត្រូវបានជ្រើសរើស?

# គោលការណ៍ការឆ្លើយតបពេលមានអាសន្ន

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់៖

1. ប្រកាសអាសន្ន ឬអាចជន្លៀសមនុស្សជុំវិញចេញ
   - ហៅសុំជំនួយប្រសិនបើចាំបាច់
2. ធានាសន្តិសុខទីតាំងកើតហេតុ
   - រឹតត្បិតការចេញចូល ទប់ស្កាត់ការចូលមកកន្លែងកើតហេតុ
   - បញ្ឈប់ប្រភពនៃឧប្បទ្ទវហេតុឬគ្រោះថ្នាក់ (ប្រសិនបើចាំបាច់ និងអាចធ្វើបាន)
   - ទប់ស្កាត់កុំឲ្យ គ្រោះថ្នាក់ រឹតតែធ្ងន់ធ្ងរ ឬទប់ស្កាត់គ្រោះថ្នាក់ដែលអាចកើតមានលើកទីពីរ (ប្រសិនបើចាំបាច់)

# គោលការណ៍ការឆ្លើយតបពេលមានអាសន្ន

3. ការរៀបចំអន្តរាគមន៍

- កំណត់តួនាទី និងភារកិច្ចជាក់លាក់ (ប្រសិនបើចាំបាច់ យោងទៅតាមតួនាទី និងការទទួលខុសត្រូវ ដូចមានពិពណ៌នាក្នុងនីតិវិធី)
- ត្រៀម PPE ដែលចាំបាច់ និងសម្ភារៈសម្រាប់អន្តរាគមន៍ (ចាំបាច់ត្រូវមានត្រៀមរួចជាស្រេច)
- ពាក់ PPE

4. ចាប់ដំណើរការអន្តរាគមន៍

5. រាយការណ៍ ករណីឧបទ្ទវហេតុ ឬគ្រោះថ្នាក់

# ទម្រង់រាយការណ៍ឧប្បទ្ទវហេតុ

ចាំបាច់ត្រូវបំពេញ ទម្រង់រាយការណ៍ឧប្បទ្ទវហេតុ និងដាក់ជូនឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន (ទៅប្រធានមន្ទីរពិសោធន៍)



**Incident Reporting Form**

Use this form to report any workplace accident, injury, incident, close call or illness.
Return completed form to the Operations Supervisor, or Management.

**This is documenting an:**

☐ Lost Time/Injury ☐ First Aid ☐ Incident ☐ Close Call ☐ Observation

**Details of person injured or involved** (to be filled in by person injured / involved if possible)

Person Completing Report:____________________ Date:____________________

Person(s) Involved:____________________

Equipment or Truck ID:____________________

**Event Details**

Date of Event:____________________ Location of Event:____________________

Time of Event:____________________ Witnesses:____________________

**Description of Events** (Describe tasks being performed and sequence of events):

*If more space is required please use the back of this sheet

**Was event / injury caused by an unsafe act (activity or movement) or an unsafe condition (machinery or weather)?** Please explain:

| TO BE COMPLETED ONLY IF LOST TIME/INJURY OR FIRST AID WAS REQUIRED | |
|---|---|
| Type of injury sustained: | |
| Cause of lost time/ injury or first aid: | |
| Was medical treatment necessary? | Yes____ No____<br>If yes, name of hospital or physician: |

Signature of Employee:____________________ Date:____________________

Signature of Supervisor:____________________ Date:____________________



**ACCIDENT/INCIDENT REPORT FORM** Record No:______

**Personal details**

Name:

Occupation:

Section/Dept: Date of report: / /

**Accident/incident details**

Date: Time: Date reported: / /

Location: Witness:

Reported to whom:

**Full accident/incident details –** what happened, or in the case of a near miss, what could have happened

**Injury – Nature of Injury**

☐ Contusion/crush ☐ Burn ☐ Dislocation ☐ Amputation

☐ Laceration/open wound ☐ Superficial injury ☐ Foreign body ☐ Internal injury

☐ Concussion ☐ Sprain/strain ☐ Fracture ☐ Dermatitis

**Location of Injury**

☐ Head/face ☐ Eye ☐ Internal organs

☐ Hand/fingers ☐ Shoulder/arms ☐ Trunk (other than back)

☐ Hip/leg ☐ Foot/toes ☐ Back

☐ Other (state)

**Results of accident**

Lost time injury Y / N No. of days: _____ days Workers' compensation Y / N

Treatment received: ☐ First aid ☐ Doctor ☐ Hospital

**Damage to equipment/buildings/vehicles etc.**

What was damaged?

Extent of damage:

**Contributing factors**

What were the contributing factors (if any)?

**Corrective actions**

Immediate actions

What controls can be put in place to prevent this from happening again?



**INCIDENT/ACCIDENT REPORT**

# អ្នកដែលត្រូវទំនាក់ទំនងក្នុងពេលមានអាសន្ន

- ប្រធានមន្ទីរពិសោធន៍
- ប្រធានផ្នែក
- មន្ត្រីផ្នែកសុវត្ថិភាព
- សេវាសុខាភិបាល/មន្ទីរពេទ្យក្នុងមូលដ្ឋាន
- និយោជិតដែលធ្វើការជាមួយមេរោគមានហានិភ័យមធ្យមទៅខ្ពស់ ត្រូវពាក់កាតដែលមានបញ្ជាក់កន្លែងធ្វើការរបស់ខ្លួន និង POCs ដើម្បីទំនាក់ទំនងចំពោះព័ត៌មានអំពីភ្នាក់ងារដែលខ្លួនអាចនឹងត្រូវប៉ះពាល់ជាមួយ

# ប្រអប់សម្ភារៈសម្រាប់ប្រើពេលមានអាសន្ន




ប្រអប់សង្គ្រោះបឋម




ប្រអប់ករណីកំពប់សារធាតុជីវសាស្ត្រ




ប្រអប់ករណីកំពប់សារធាតុគីមី

# នីតិវិធីពេលមានគ្រោះអាសន្ន

# ប្រភេទនៃគ្រោះអាសន្ន

- សារធាតុជីវសាស្ត្រ




- សារធាតុគីមី




- សារធាតុវិទ្យុសកម្ម




- សារធាតុបង្កអគ្គិភ័យ



# គ្រោះអាសន្នផ្នែកជីវសាស្ត្រ

តើគ្រោះថ្នាក់ផ្នែកជីវសាស្ត្រអ្វីខ្លះដែលទំនងជាអាចកើតមានក្នុងមន្ទីរពិសោធន៍?

សូមពិភាក្សាក្នុងក្រុមតូច និងរាយការណ៍ប្រាប់ថ្នាក់ទាំងមូលអំពី៖

- ចូររាប់ឈ្មោះគ្រោះថ្នាក់ផ្នែកជីវសាស្ត្រដែលអាចមាន
- នៅពេលរាប់ឈ្មោះនេះរួចហើយ សូមកំណត់រកសេណារីយ៉ូ (ដើម្បីឈានទៅកំណត់នីតិវិធីពេលមានអាសន្ន) ដែលអ្នកចង់បង្កើត








Biological Spill Cleanup









# សេណារីយ៉ូគ្រោះអាសន្នផ្នែកជីវសាស្ត្រ

- ការកំពប់តិចតួចនៅក្នុង BSC
- ការកំពប់ធ្ងន់ធ្ងរនៅក្នុង BSC
- ការកំពប់តិចតួចនៅក្រៅ BSC
- ការកំពប់ធ្ងន់ធ្ងរនៅក្រៅ BSC ដោយមានហានិភ័យនៃការឆ្លងមេរោគសាយភាយតាមខ្យល់
- ការកំពប់ក្រៅមន្ទីរពិសោធន៍ រួមទាំងការកំពប់កាកសំណល់ក្នុងពេលដឹកជញ្ជូននៅក្នុងមន្ទីរពិសោធន៍
- ការបែកបំពង់នៅក្នុង centrifuge (អាចមានស្ថានភាពខុសៗគ្នា)
- របួសមុតម្ជុល ឬការប៉ះពាល់មេរោគដោយចៃដន្យដទៃទៀតតាមរយៈការមុតម្ជុល ឬការដាច់រលាត់
- ការខ្ទាតចូលក្នុងភ្នែក ឬក្នុងមាត់
- ការប៉ះពាល់ដោយចៃដន្យជាមួយសារធាតុសាយភាយក្នុងខ្យល់
- ការលេបចូលក្នុងពោះដោយចៃដន្យ

# ឧទាហរណ៍

ការកំពប់ធ្ងន់ធ្ងរក្នុងមន្ទីរពិសោធន៍ (ខាងក្រៅ BSC) ដែលមានហានិភ័យនៃការឆ្លងមេរោគតាមខ្យល់

## ការប្រកាសអាសន្ន

1. ប្រកាសអាសន្នដល់មនុស្សនៅជុំវិញ និងជន្លៀសមនុស្សចេញពីមន្ទីរពិសោធន៍
2. ហាមឃាត់មិនឲ្យមានការចេញចូលទៅកាន់មន្ទីរពិសោធន៍
3. ប្រាប់ទៅប្រធានមន្ទីរពិសោធន៍ និង/ឬ មន្ត្រីជីវសុវត្ថិភាព

## សន្តិសុខ នៅទីតាំងកើតហេតុ

4. ចាកចេញរយៈពេល ៣០ នាទី ដើម្បីឲ្យមេរោគរសាត់តាមខ្យល់ត្រូវបានលុបបបំបាត់

# ឧទាហរណ៍

## រៀបចំ

5. ក្នុងអំឡុងពេលនោះ ត្រូវរៀបចំឧបករណ៍ និងសម្ភារៈដែលត្រូវការ
6. ពាក់ PPE (ឈុតពាក់ពីក្រៅ, ស្បែកជើងគ្របពីលើ ម៉ាស់FFP3 និង ស្រោមដៃកៅស៊ូ ឬ nitrile

## អន្តរាគមន៍

7. ក្រោយរយៈពេល ៣០ នាទី សូមចូលទៅក្នុងពិសោធន៍វិញ
8. ត្រូវគ្របបរិវេណកំពប់ដោយប្រុងប្រយ័ត្ន ដោយប្រើក្រដាសជក់ទឹក ឬក្រណាត់ជ្រលក់ថ្នាំសំលាប់មេរោគ
9. ទុកឲ្យសារធាតុសំលាប់មេរោគដំណើរការរយៈពេល XX នាទី (មានបញ្ជាក់ក្នុងនិតិវិធី)

# ឧទាហរណ៍

10. បាញ់សារធាតុសំលាប់មេរោគលើផ្ទៃជុំវិញ (អេតាណុល ឬសារធាតុដទៃទៀត ដូចមាន បញ្ជាក់ក្នុងនិតិវិធី )
11. ប្រសិនបើមានវត្ថុមានកំទេចកែវ ឬមានការសង្ស័យថាមានកំទេចកែវ ត្រូវពាក់ស្រោមដៃ

    ក្រាស់បន្ថែមពីលើស្រោមដៃកៅស៊ូ ឬ nitrile
12. ប្រមូលកើបសម្ភារៈដែលជក់ស្រូបយកសំណល់កំពប់ និងកំទេចកំទីដែលអាចមាន ដោយប្រើប្រាស់ប្រដាប់ចូកសំរាម និង/ឬ ដង្កៀបចាប់ ហើយបោះចោលក្នុងថង់អូតូក្លាវ ឬភាជនៈផ្ទុកកាកសំណល់ជីវសាស្រ្ត
13. ផ្តិតយកសារធាតុរាវដែលនៅសល់ដោយប្រើក្រណាត់ជក់ទឹករហូតដល់ឥដ្ឋស្អាត និងស្ងួត
14. ដោះស្រោមដៃក្រាស់ចេញ ហើយផ្លាស់ទៅប្រើស្រោមដៃកៅស៊ូ ឬnitrile

# ឧទាហរណ៍

15. បាញ់សារធាតុសំលាប់មេរោគលើបរិវេណកំពប់និងបរិវេណជុំវិញ
16. ដោះស្រោមដៃ និង PPE ដទៃទៀតចេញ រួចបោះចោលរបស់ទាំងនោះដោយចាត់ទុកជាកាកសំណល់មានមេរោគ
17. លាងដៃជាមួយសាប៊ូ
18. ស្នើសុំឲ្យមានការសម្អាតទីតាំង(ក្នុងករណីគ្រោះថ្នាក់ធ្ងន់ធ្ងរប៉ុណ្ណោះ) ពីប្រធានមន្ទីពិសោធន៍ ឬមន្ត្រីជីវសុវត្ថិភាព

**របាយការណ៍**ឧបទ្ទវហេតុ ឬគ្រោះថ្នាក់

19. របាយការណ៍ឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ទៅកាន់មន្ត្រីជីវសុវត្ថិភាព

… និង ជាចុងក្រោយ

20. បំពេញឲ្យមានជាថ្មីឡើងវិញនូវសម្ភារៈដែលបានប្រើប្រាស់អស់

# ឧទាហរណ៍

ការរាយការណ៍អំពីឧប្បទ្ទវហេតុ គួរធ្វើឡើងដោយប្រើប្រាស់ទម្រង់បទដ្ឋាន និងមានមជ្ឈមណ្ឌលកណ្ដាលសម្រាប់ទទួលសំរេច (ហេតុនេះ ចាំបាច់ត្រូវរាយការណ៍ទៅអ្នកទទួលបន្ទុកផ្នែក (ជីវ)សុវត្ថិភាព ដោយសារគ្រោះថ្នាក់និងប្រភេទនៃឧប្បទ្ទវហេតុ គួរមានការវិភាគលើករណីគ្រោះថ្នាក់នោះជាមុនសិន។

# សម្ភារៈ ឧបករណ៍ នៅក្នុងប្រអប់សម្រាប់ប្រើប្រាស់ពេលមានករណីកំពប់

## លំហាត់ក្រុម៖

សូមប្រើឧទាហរណ៍ខាងដើមជាករណីសិក្សា

- តើអ្នកនឹងដាក់អ្វីខ្លះនៅក្នុងប្រអប់ប្រើប្រាស់ពេលមានការកំពប់?
- តើអ្នកនឹងដាក់ប្រអប់ប្រើប្រាស់ពេលមានការកំពប់នៅទីណា?
- បន្ថែមលើប្រអប់ប្រើប្រាស់ពេលមានករណីកំពប់នេះ តើអ្នកត្រូវការសម្ភារៈអ្វីផ្សេងបន្ថែមទៀត ឬទេ?
- តើរបស់ទាំងនោះត្រូវមានទីតាំងនៅត្រង់ណា?

# ប្រអប់ប្រើប្រាស់ពេលមានការកំពប់ជីវសាស្ត្រ




មានប្រអប់ប្រើប្រាស់ពេលមានការកំពប់ ដាក់លក់ស្រាប់ ដោយជាទូទៅគឺមានតម្លៃថ្លៃ។ ហេតុនេះ ការរៀបចំសម្ភារៈដាក់ក្នុងប្រអប់ប្រើប្រាស់ពេលមានការកំពប់ “ធ្វើខ្លួនឯង” ជាទូទៅតែងមានអត្ថប្រយោជន៍ច្រើនជាង។

# វត្ថុមុតស្រួច







- មានហានិភ័យខ្ពស់ក្នុងការចម្លងមេរោគនៅក្នុងឈាមតាមផ្លូវផ្សេងក្រៅពីមាត់ និងផ្លូវរំលាយអាហារ (HBV, HCV និង HIV)
- មានហានិភ័យមួយចំនួនផងដែរជាមួយភ្នាក់ងារជីវសាស្ត្រដទៃទៀត (ឆ្លងរួចពីឧបសគ្គការពារបែបធម្មជាតិភាគច្រើន)
- សកម្មភាពប្រឈមហានិភ័យខ្ពស់
  - ការកាន់ម្ជុល កាំបិតវះកាត់ កន្ត្រៃ...
  - **ការបិទគម្របម្ជុលវិញ (ហានិភ័យខ្ពស់)**
  - ការចាប់កាន់វត្ថុមុតស្រួច និងកញ្ចក់បែកនៅក្នុងសំរាម

# នីតិវិធីសម្រាប់ករណីមុតវត្ថុមុតស្រួច

1.លាងរបួសជាមួយទឹកក្តៅឧណ្ហៗ និងសាប៊ូប្រសិនបើមាន។ សូមប្រើទឹកត្រជាក់ ប្រសិនបើគ្មានទឹកក្តៅឧណ្ហៗ។

2.ស្វែងរកការព្យាបាលឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន

3.រាយការណ៍រាល់ឧប្បទ្ទវហេតុកើតឡើងទៅកាន់ប្រធានមន្ទីរពិសោធន៍ និងគ្រប់របួសទាំងអស់ដែលនឹងអាចកើតចេញពីឧប្បទ្ទវហេតុក្នុងមន្ទីរពិសោធន៍ ឬក្នុងករណីភ្លាត់មានឧប្បទ្ទវហេតុ គួរត្រូវបានរាយការណ៍ប្រាប់ទៅបុគ្គលទាំងនេះ។

# នីតិវិធីសម្រាប់ករណីមុតវត្ថុមុតស្រួច

4.ប្រសិនបើឧបទ្ទវហេតុនោះមានសក្តានុពលទំនងប៉ះពាល់ជាមួយវត្ថុធាតុមានមេរោគឆ្លង នោះចាំបាច់ត្រូវស្វែករកការព្យាបាលវេជ្ជសាស្ត្រជាបន្ទាន់។ ក្នុងស្ថានភាពមិនអាចដឹងពីហានិភ័យនៃការប៉ះជាមួយវត្ថុធាតុមានមេរោគឆ្លង ឬមិនប្រាកដក្នុងចិត្ត ហើយរបួសបានកើតឡើងនៅក្នុងបរិវេណស្រាវជ្រាវវេជ្ជសាស្ត្រ របួសនោះគួរត្រូវបានព្យាបាលដោយចាត់ទុកថាមានលទ្ធភាពប៉ះជាមួយវត្ថុធាតុមានមេរោគឆ្លង និងត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់អ្នកទទួលបន្ទុកផ្នែកជីវសុវត្ថិភាពដើម្បីអាចឲ្យគេចាប់ផ្តើមធ្វើការវាយតម្លៃហានិភ័យ។

# ករណីអាសន្នពេលមានកំពប់សារធាតុគីមី




| ស្រាល | ធ្ងន់ធ្ងរ |
|---|---|
| • ប្រកាសអាសន្នទៅអ្នកនៅក្នុងបរិវេណកន្លែងកំពប់<br>• ពាក់ឧបករណ៍ការពារទាំងវ៉ែនតាឆ្លុះសុវត្ថិភាព ស្រោមដៃ និងអាវមន្ទីរពិសោធន៍មានដៃវែង<br>• ចៀសវាងដកដង្ហើមស្រូបយកសារធាតុហួតចេញពីការកំពប់<br>• រាំងខ្ទប់ការកំពប់ឲ្យស្ថិតក្នុងបរិវេណតូច<br>• ប្រើប្រាស់ប្រអប់សង្គ្រោះសមស្រប ដើម្បីបន្សាប និងផ្ចិតយកអាស៊ីត និងបាសមិនមែនសរីរាង្គ។ ប្រមូលសារធាតុសេសសល់ដាក់ចូលក្នុងភាជនៈ និងបោះចោលក្នុងធុងដោយចាត់ទុកជាកាកសំណល់សារធាតុគីមី<br>• សម្រាប់សារធាតុគីមីដទៃទៀត ត្រូវប្រើប្រអប់សង្គ្រោះសមស្រប ឬផ្ចិតស្នាមកំពប់ដោយ vermiculite ខ្សាច់ស្ងួត ឬ diatomaceous earth។ ប្រមូលកាកសំណល់សេសសល់ ដាក់ចូលក្នុងភាជនៈ និងបោះចោលក្នុងធុងដោយចាត់ទុកជាកាកសំណល់គីមី | • យកចិត្តទុកដាក់ចំពោះអ្នករងរបួស ឬអ្នកប៉ះសារធាតុគីមី ហើយនាំពួកគេចេញពីកន្លែងដែលប៉ះពាល់សារធាតុនោះ<br>• ប្រកាសអាសន្នប្រាប់អ្នកនៅក្នុងមន្ទីរពិសោធន៍ឲ្យជន្លៀសចេញ<br>• ប្រសិនបើសារធាតុកំពប់នោះអាចឆេះបាន ត្រូវបិទប្រភពផ្កាភ្លើង និងប្រភពកម្ដៅ<br>• ហៅរកជំនួយ<br>• បិទទ្វារទៅកាន់បរិវេណរងផលប៉ះពាល់<br>• ឲ្យអ្នកមានការយល់ដឹងអំពីឧបទ្ទវហេតុ និងមន្ទីរពិសោធន៍ ជួយដល់បុគ្គលិកសង្គ្រោះបន្ទាន់ |

រាយការណ៍ករណីឧបទ្ទវហេតុនោះភ្លាមៗទៅកាន់ប្រធានមន្ទីរពិសោធន៍/PI។ ផ្តល់របាយការណ៍អំពីឧបទ្ទវហេតុ។

# ករណីគ្រោះអាសន្នពេលកំពប់សារធាតុវិទ្យុសកម្ម




| ស្រាល | ធ្ងន់ធ្ងរ |
|---|---|
| • ប្រកាសអាសន្នទៅអ្នកនៅក្នុងបរិវេណជុំវិញអំពីការកំពប់<br>• ជូនដំណឹងដល់មន្ត្រីសុវត្ថិភាពវិទ្យុសកម្ម របស់សាលារៀន<br>• ពាក់ឧបករណ៍ការពារខ្លួន រួមទាំងវ៉ែនតាឆ្លុះសុវត្ថិភាព ស្រោមដៃប្រើរួចបោះចោល ស្រោមស្បែកជើង និងអាវមន្ទីរពិសោធន៍ដៃវែង<br>• ដាក់ក្រដាសជក់ទឹកលើវត្ថុរាវដែលកំពប់។ ដាក់កន្សែងផ្សើមជាមួយទឹកលើសារធាតុរឹងដែលកំពប់<br>• ប្រើប្រាស់ដង្កៀបចាប់កន្សែងដាក់ក្នុងថង់ប្លាស្ទិក។ បោះចោលទៅក្នុងប្រអប់កាកសំណល់វិទ្យុសកម្ម<br>• ពិនិត្យតាមដានបរិវេណ ដៃ និងស្បែកជើង ក្រែងមានការប្រឡាក់ ដោយប្រើប្រាស់ប្រដាប់ស្ទង់ ឬវិធីសាស្ត្រសមស្រប<br>• លាងសម្អាតម្តងហើយម្តងទៀតរហូតទាល់តែពិនិត្យរកលែងឃើញការប្រឡាក់ | • យកចិត្តទុកដាក់ចំពោះអ្នករបួស ឬអ្នកប្រឡាក់ជាតិវិទ្យុសកម្ម និងនាំពួកគេចេញពីកន្លែងដែលអាចប៉ះពាល់សារធាតុវិទ្យុសកម្ម<br>• ឲ្យបុគ្គលិកដែលសង្ស័យថាអាចមានប្រឡាក់សារធាតុវិទ្យុសកម្មនៅមួយកន្លែង រហូតទាល់តែគេបានទទួលការពិនិត្យ នឹងបង្ហាញថា ពុំមានការប្រឡាក់ទេ<br>• ជូនដំណឹងដល់មន្ត្រីសុវត្ថិភាពវិទ្យុសកម្ម របស់សាលារៀន<br>• បិទទ្វាទៅកាន់បរិវេណរងផលប៉ះពាល់<br>• ឲ្យអ្នកការយល់ដឹងអំពីឧបទ្ទវហេតុ និងមន្ទីរពិសោធន៍ ជួយសម្រួលដល់បុគ្គលិកសង្គ្រោះបន្ទាន់ |

របាយការណ៍ករណីឧបទ្ទវហេតុនោះភ្លាមៗទៅកាន់ប្រធានមន្ទីរពិសោធន៍/PI។ ផ្តល់របាយការណ៍អំពីឧបទ្ទវហេតុ។

# ករណីគ្រោះអាសន្នអគ្គិភ័យ

FIRE

| ស្រាល | ធ្ងន់ធ្ងរ |
| --- | --- |
| • ប្រកាសអាសន្នដល់មនុស្សក្នុងមន្ទីរពិសោធន៍ និងចុចកណ្ដឹងប្រកាសអាសន្នឲ្យរោទ៍ឡើង<br>• ពន្លត់អគ្គិភ័យ ឬប្រើប្រាស់ប្រដាប់ពន្លត់អគ្គិភ័យសមស្រប<br>• តម្រង់ប្រដាប់ពន្លត់អគ្គិភ័យទៅត្រង់ប្រភពភ្លើង<br>• ជានិច្ចជាកាលត្រូវរក្សាច្រកចេញឲ្យអាចចេញ<br>• គេចចេញពីផ្សែង | • ប្រកាសអាសន្នដល់មនុស្សក្នុងបរិវេណនោះឲ្យជន្លៀសចេញ<br>• ចុចកណ្ដឹងប្រកាសអាសន្ននៅជិតបំផុតឲ្យរោទ៍ឡើង ឬហៅទៅលេខទូរស័ព្ទរបស់សន្តិសុខ<br>• បិទទ្វារ ដើម្បីរាំងខ្ទប់ភ្លើង<br>• ជន្លៀសចេញទៅកាន់បរិវេណសុវត្ថិភាព ឬចាកចេញពីអគារដោយប្រើប្រាស់ជណ្ដើរជើង សូមកុំប្រើជណ្ដើរយន្តប្រអប់<br>• ឲ្យអ្នកមានការយល់ដឹងអំពីឧបទ្ទវហេតុ និងមន្ទីរពិសោធន៍ ជួយសម្រួលដល់បុគ្គលិកសង្គ្រោះបន្ទាន់ |

**សំលៀកបំពាក់ត្រូវភ្លើងឆេះ**

- ប្រមៀលជននោះនៅលើឥដ្ឋ ដើម្បីពន្លត់អណ្តាតភ្លើង ឬពន្លត់ដោយទឹកប្រសិនបើកន្លែងមុជទឹកសុវត្ថិភាពនៅជាប់នោះ
- ស្វែងរកការព្យាបាលវេជ្ជសាស្ត្រ ប្រសិនបើចាំបាច់
- រាយការណ៍ឧបទ្ទវហេតុទៅប្រធានផ្នែក

# ការបណ្តុះបណ្តាលការឆ្លើយតបក្នុងពេលមានអាសន្ន

- ការសង្គ្រោះបឋម
- ការជន្លៀស/ការសំលាប់មេរោគសម្រាប់បុគ្គលិករងរបួស
- ការជ្រើសរើស/ការប្រើប្រាស់ PPE
- ការវាយតម្លៃប្រភពគ្រោះថ្នាក់នៅនឹងកន្លែង
- នីតិវិធីក្នុងការសំលាប់ មេរោគ
- ការរាយការណ៍
- ការធ្វើសមយុទ្ធតាមពេលវេលាកំណត់

- ការពិនិត្យឡើងវិញក្រោយពេលធ្វើសកម្មភាព ត្រូវធ្វើឡើងដើម្បីកំណត់រកបទពិសោធន៍ទទួលបាន និងដាក់បញ្ចូលបទពិសោធន៍ ទាំងអស់នេះ ទៅក្នុងការធ្វើបច្ចុប្បន្នភាពផែនការពេលមានអាសន្ន និងការហាត់សមនាពេលអនាគត
- បន្តការពិនិត្យឡើងវិញ និងកែសម្រួលផែនការ ឧបករណ៍ នីតិវិធី និងបរិក្ខារឲ្យមានបច្ចុប្បន្នភាព

# ការកំពប់ក្រៅម៉ោងការងារ/គ្រោះថ្នាក់

- នីតិវិធីនៅនឹងកន្លែង

-បើមានការកំពប់វការសំខាន់ដំបូងវគឺរាំងផ្ទប់កុំឲ្យសាយភាយ (សម្អាត និងរាយការណ៍)

-ការកំពប់ដែលមិនបានរាំងផ្ទប់មិនឲ្យសាយភាយ នឹងក្លាយជាការគំរាម

- ជូនដំណឹងដល់មណ្ឌលវេជ្ជសាស្ត្រអំពីការរងរបួស/ការប៉ះជាមួយការកំពប់

- ជូនដំណឹងដល់ប្រធានមន្ទីរពិសោធន៍ ដើម្បីពិគ្រោះយោបល់

-ការសម្រេចចិត្តក្នុងការផ្តួចផ្តើមផែនការ

# ម៉ោងអនុវត្ត!

# សេណារីយ៉ូស្តីពីពេលមានគ្រោះអាសន្ន៖

សូមធ្វើការជាក្រុម៖

1) ជ្រើសរើសសេណារីយ៉ូ៖ គីមី វិទ្យុសកម្ម ជីវសាស្រ្ត អគ្គីភ័យ
2) រៀបរាប់អំពីជំហាននីតិវិធីពេលមានអាសន្ន
3) តើត្រូវរាយការណ៍ទៅនរណា?
4) បំពេញរបាយការណ៍អំពីឧបទ្ទវហេតុ
5) រាយការណ៍ដល់ក្រុមទាំងមូល